អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦

# សេចក្តីថ្លែងការណ៍
# របស់អង្គភាពគាំពារការការពារក្តីអំពីមរណភាពរបស់មេធាវី John R.W.D. Jones

អង្គភាពគាំពារការការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) មានទុក្ខក្រៀមក្រំ នៅពេលបានទទួលដំណឹងមរណភាពរបស់មេធាវី John R.W.D. Jones ដែលជាមេធាវីអន្តរជាតិការពារក្តីអ្នកស្រី អ៊ីម ចែម។

លោក John R.W.D. Jones គឺជាមេធាវីដ៏ចំណានម្នាក់ និងបានផ្តល់ដំបូន្មានល្អៗ ព្រមទាំងជាបុគ្គលដែលគួរឱ្យចង់ធ្វើការជាមួយ។ លោក John R.W.D. Jones មានបទពិសោធន៍ការពាររឿងក្តីនៅសាលាក្តីសំខាន់ៗ ព្រមទាំងបានធ្វើជាគ្រូឧទ្ទេសនាម និងបោះពុម្ពផ្សាយស្នាដៃនិពន្ធជាច្រើន។

អ្នកផងទាំងឡាយបានកោតសរសើរលោក John R.W.D. Jones ដែលគោរពវិជ្ជាជីវៈ ស្មោះត្រង់ និងសុភាពរាបសា ទោះជានៅពេលបំពេញបេសកកម្មនៅមូលដ្ឋាន បំពេញការងារនៅអយ្យការ បំពេញការងារនៅអង្គជំនុំជម្រះ បំពេញការងារជាមួយភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬជាមួយមេធាវីការពារក្តីដទៃទៀត។ ការចូលរួមចំណែករបស់លោកចំពោះសំណុំរឿង និងការតាំងចិត្តខ្ពស់ចំពោះយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ជារួម គឺជាគំរូមួយសម្រាប់យើងទាំងអស់គ្នា។ យើងទាំងអស់ពិតជាមានសេចក្តីសង្វេគចំពោះលោក John R.W.D. Jones ជាពន់ពេកដែលបានលាចាកលោកយើងទៅហើយ។

មេធាវីការពារក្តី អ៊ឹម ចែម អង្គភាពគាំពារការការពារក្តី និងការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក សូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំចំពោះក្រុមគ្រួសារ មិត្តភ័ក្តិ និងសហការីរបស់លោក John R.W.D. Jones។

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ **www.eccc.gov.kh**
**National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555 www.eccc.gov.kh**
Original EN: 01225565-01225565